

តើវាពិត ជា ដំណោះស្រាយ ?

ការសម្រុះសម្រួលគ្នា រវាង គណបក្សកាន់អំណាច និង សង្គ្រោះជាតិ ដែលវាអាចកើតមានជាថ្មី នៅពេលខាងមុខ តើវាពិត ជា ដំណោះស្រាយ នយោបាយ នៅស្រុកខ្មែរ ដែរឬទេ ?

យើងលើកសួរ សំនួរនេះ ព្រោះ តាំងពីបោះឆ្នោត ២០១៣ មក យើងឃើញមាន ការសម្រុះសម្រួលគ្នា ជានិច្ច រវាង គណបក្ស ទាំងពីរនេះ នៅក្នុង រឬជម៌សន្ទនា តែ លទ្ធផល វាគ្មានមានទាល់តែសោះ សំរាប់ប្រជាជាតិខ្មែរ ព្រោះ លទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរ វាដុនដាប រហូត សព្វថ្ងៃ ស្រុកខ្មែរ ក្លាយជាប្រទេសផ្តាច់ការ រណបផ្តាច់មុខ ចិន-យួន កុម្ម្ងយនិស្ត ដែលជា ចារី នៃ ក្រោះមហន្តរាយនយោបាយខ្មែរ តាំងពីឆ្នាំ ១៩៧០ មកម្លេះ។

កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា

កិច្ចព្រមព្រៀង នៃ សន្តិភាព ២៣ តុលា ១៩៩១ វាគ្រាន់តែជា រយាលពេលមួយ សំរាប់ ប្រទេស ចិន និង យួន ស្វែងរក ដំណោះស្រាយ នៃ ទំនាស់ របស់គេ លើ លក្ខន្តិក:ខ្មែរ សំរាប់គេចែកប្រយោជន៍គ្នា។ នៅពេល ចិន និង យួន គេ មានដំណោះស្រាយ រួម គេគ្មានកង្វល់អ្វី នូវ ការអនុវត្តន៍ ឲបានម៉ត់ចត់ នៃ កិច្ចព្រមព្រៀងនោះឡើយ។ ជាឧទាហរណ៍ គ្រាន់តែ បោះឆ្នោតរួច

តើវាពិត ជា ដំណោះស្រាយ ?

ស្រេច នៅឆ្នាំ ១៩៩៣ ភាគីខ្មែរ រណបយួន បំពានជាក់ស្តែងភ្លាម លើ កិច្ចព្រមព្រៀង ដោយមិនព្រមទទួលលទ្ធផល នៃការបោះឆ្នោត រហូត កំញើញ បង្កើត ដំបន់អបគមន៍។ សព សម្តេចសីហនុ នៅពេលនោះ ដែលជា ប្រធាន ក្រុមព្រឹក្សាជាតិជាន់ខ្ពស់ (C.N.S) ព្រះអង្គ ក្លានប្រតិកម្ម ក្លៀវក្លា បង្ខំ១ អ.ស.ប ដែលមាន អាណត្តិ ជា អាជ្ញាធរ បណ្តោះអាសន្ន របស់អង្គការសហប្រជាជាតិ នៅកម្ពុជា (APRONUC) ទទួលការខុសត្រូវ និងបន្តបេសកកម្ម ដើម្បី ដោះស្រាយ ១រួចស្រេច នូវ ការបំពាននោះទេ ប៉ែរជា សម្រុះសម្រួល បង្កើត រដ្ឋាភិបាល ក្បាលពីរ ដឹកនាំដោយ សហរដ្ឋមន្ត្រី ទី១ ទី២ (រណ្ណឫទ្ធិ-ហ៊ុនសែន) ដែលជា ដំណោះស្រាយ ផ្ទុយពីស្តារតី នៃ កិច្ចព្រមព្រៀង នៃ សន្តិភាព។ ការសម្រុះសម្រួល បដិធម្មជាតិ[1]នេះ ជា ឱសថ ធ្វើ១ អំណាចផ្តាច់ការ រស់ឡើងវិញបាន នៅស្រុកខ្មែរ : ដូចនេះ រដ្ឋប្រហារ នៅឆ្នាំ ១៩៩៧ ជា ផលា នៃ នយោបាយ អឬច្ចុយភាព (politique illogique) របស់សព សម្តេចសីហនុ និង អសមត្ថកិច្ច របស់ទ្រង់ រណ្ណឫទ្ធិ ក្នុងការគ្រប់គ្រង ជ័យជំនះ របស់ខ្លួន។ តែ អវត្តមាន នៃ ចលនា ខ្លាំងក្លា នៃ អ្នកប្រជាធិបតេយ្យសេរីពិតប្រាកដ នៅក្នុង អវកាស នយោបាយ នៅពេលនោះ ក៏ជា កត្តាមួយដែរ នាំ១ ពួកអ្នកផ្តាច់ការ គ្រប់និន្នាការ ក្តាប់ អំណាចនយោបាយបាន។ ត្រូវកត់សំគាល់ថា សព សម្តេច សីហនុ និង

[1] បដិធម្មជាតិ ; ប្រឆាំងនឹងធម្មជាតិ ; anti-nature។

តើវាពិត ជា ដំណោះស្រាយ ?

ពួកអ្នករាជានិយម ដាច់ខាត ភ្លាន់ស្ការតី ជា ជនប្រជាធិបតេយ្យ នោះឡើយ ព្រោះ អត្ថរស់ នៃ រាជានិយមខ្មែរ ជា រាជានិយមផ្តាច់ការ (monarchie absolue) : ជាឧទាហរណ៍ ក្រោយពីស្រុកខ្មែរ ទទួលបានឯករាជ្យ សព សម្តេច សីហនុ ទ្រង់ ធ្វើអំពើគ្រប់បែបយ៉ាង ប្រឆាំងនឹង រដ្ឋធម្មនុញ្ញ មានខ្លឹមសារ ជា របបប្រជាធិបតេយ្យសេរី ដើម្បី ប្រកាស្ថាបនា នូវ រាជានិយមផ្តាច់ការ។ របប សង្គមរាស្ត្រនិយម គឺជា រាជានិយមផ្តាច់ការ ក្លែងខ្លួនតែប៉ុណ្ណោះ ព្រោះជារបប មានស្តេចពីរអង្គ : មួយព្រះអង្គ ជា ស្តេចសោយរាជ្យ មួយទៀត ជា ប្រមុខរដ្ឋ កាន់អំណាចផ្តាច់ការអស់មួយជីវិត : នេះ មិនជា រាជានិយមផ្តាច់ការ ទេហ: ?

ឥទ្ធិពល នៃ ចិន និង យួន

តាំងពីឆ្នាំ ១៩៩៧ មក ស្រុកខ្មែរ ដើរចេញពីផ្លូវប្រជាធិបតេយ្យសេរី បាត់ទៅហើយ។ ដូចនេះ ការបោះឆ្នោតទាំងឡាយ បន្ទាប់ ពីពេលនោះមក វាគ្រាន់តែជា ការក្លែង ១ មតិអន្តរជាតិ មើលច្រឡំថា នៅស្រុក មាន លទ្ធិប្រជាធិបតេយ្យសេរី ដូច្នេះ របបដឹកនាំ ជា របប ស្របច្បាប់ នៅក្នុងប្រទេសមានអធិបតេយ្យភាព ពេញលេញ មិនអាច បរទេសណា បំពានបាននោះឡើយ។ ពី អាណ្ណតិ សភាពជាតិ មួយទៅមួយទៀត គ្រប់គណបក្សនយោបាយ តែងតែធ្វើសហការ ជាមួយ គណបក្សកាន់អំណាច ដើម្បី ជួយពង្រឹង ដោយមិនដឹងខ្លួនក្តី ដឹងខ្លួនក្តី អំណាចផ្តាច់ការ ជាអំណាចរណបយួន ដែល អនុវត្ត នូវ

តើវាពិត ជា ដំណោះស្រាយ ?

នយោបាយ សមាហរណកម្ម ស្រុកខ្មែរ ឲចូលទៅក្នុង ប្រទេសវៀតណាម តាម គោលវិធី នៃ ការបញ្ជូល ប្រជាជនយួន រាប់លាន ចូលមករស់នៅក្នុងស្រុកខ្មែរ និង យួនបនីយកម្ម នៃ ថ្នាក់ដឹកនាំ នៅក្នុង រដ្ឋបាល និង រាជរដ្ឋាភិបាលខ្មែរ។ ដូច្នេះ ស្រុកខ្មែរសព្វថ្ងៃ មិនមែនជា ប្រទេស នៅក្រោមអាណានិគមយួននោះទ្បើយ ក៏ វាក្លាយជា ស្រុកយួនតែម្តង តែមាន លក្ខន្តិក: ជាដំបន់ពិសេសមួយ របស់វៀតណាម ដូចគ្នានឹង ប្រទេសលាវនោះដែរ។ ប្រទេសចិន ទទួលស្គាល់ លទ្ធការណ៍ (fait accompli) ក្នុងនាម បងប្អូនមាតាតែមួយផង, កាតព្វកិច្ច រវាង បក្សកុម្មុយនិស្តផង និង នយោបាយទាល់ច្រក របស់ខ្លួន នៅ ស្រុកខ្មែរ ក្រោយ វៀតណាម វាយ រំលំ កម្ពុជាប្រជាធិបតេយ្យ បាន។ ដូចនេះ ចិន តែងតែទុក វៀតណាម ជា ប្អូនបង្កើត តែក្បាលរឹង ហ៊ានប្រឆាំងនិងខ្លួន នៅពេលណា ដែលវៀតណាម គេទុកប្រយោជន៍គេជាត្រីមុខ។ តែ គេក៏អាច សួរថា តើ ចិន ចាញ់ បោកយួនខាងជើង ជួយឲមានជ័យជំនះ លើ យួនខាងត្បូងរួចហើយ បែរជា រលាស់ខ្លួនចេញពីខ្លួន ទៅចងសម្ព័ន្ធមិត្តជាមួយ សហភាពសូវៀត ដើម្បី ឈ្លានពានស្រុកខ្មែរ ដែលជាប្រទេស នៅក្រោមអាណាព្យាបាលចិន នៅពេលនោះ ?

វាក្យសព្ទ ‹ចាញ់បោក› វា ដូចជាខ្លាំងបន្តិច ព្រោះ ចិន ជា មហាអំណាចមួយ នៅ អាស៊ី តែ បើ និយាយថា ចិន ធ្វើនយោបាយ ច្រឡំ ចំពោះស្រុកខ្មែរ ដូចជា គប្បីជាង។ ច្រឡំបែបណា ? ចិន

តើវាពិត ជា ដំណោះស្រាយ ?

មានលទ្ធភាព ដោយមាន អាមេរិកាំង រួមផង ដោះស្រាយ បញ្ហាខ្មែរ នៅក្នុង ក្របខណ្ឌ នៃ កិច្ចព្រមព្រៀង នៅ ប៉ារីស រវាងសហរដ្ឋអាមេរិក នឹង វៀតណាមខាងជើង ដែលបាន ចុះហត្ថលេខានៅថ្ងៃ ទី២៧ ខែ មករា ១៩៧៣ បង្ហែមបង្ហែម ភាគីយុទ្ធការីខ្មែរ ជា កម្លាំងប្រជាជាតិខ្មែរតែមួយ ដើម្បី សន្តិភាព និង អព្យាក្រិតខ្មែរ ពិតប្រាកដ នៅចំពោះមុខ មហាកម្លាំងយួនទាំងពីរ រួបរួមគ្នាតែមួយ។ តែចិនជ្រើសរើសផ្លូវ បដិវត្តន៍ដាច់ខាត ដោយ១ ភាគី ខ្មែរក្រហម បដិសេធ ទាំងស្រុង នូវ កិច្ចព្រមព្រៀងសន្តិភាព និង អោយ កម្ពុជាប្រជាជិបតេយ្យ អនុវត្ត នយោបាយ តិរច្ឆាន ដែលជានយោបាយ រុះយកចេញ១អស់ នូវកម្លាំងប្រជាជាតិខ្មែរ ទុកតែកម្លាំងបក្សកុម្មុយនិស្ត ដែលជា កម្លាំងសិប្បនិម្មិត នៅក្នុងសង្គមខ្មែរ។ បន្ទ្យទ្ធកម្ម នេះ ជាជ័យជំនះ របស់មហាវៀតណាម មុនថ្ងៃ ទី៧ មករា ១៩៧៩ ព្រោះកងទ័ពយួន រង់ចាំតែ សុទិនល្អ ដើម្បី យាត្រា ចូលស្រុកខ្មែរ ស្តុតទ្រុឌ នូវ កម្លាំងជាតិ ក្រោមទង់ ជា កងទ័ពរំដោះ ប្រជាពលរដ្ឋខ្មែរ ពី របបប្រល័យពូជសាសន៍ ដែលមាន ទីប្រឹក្សា និង អ្នកជំនាញចិន នៅពេញស្រុក។ មូលហេតុ នៃការរំដោះនេះ វាមានយ៉ាងហោចណាស់ នៅក្នុងចិត្ត នៃប្រជាជនរងគ្រោះខ្មែរ ភាគច្រើន នៅពេលនោះ ទោះបី អ្នកទាំងនោះ ជា អ្នកជាតិ និយម និង អ្នកស្នេហាជាតិ ក៏ដោយ។

តើវាពិត ជា ដំណោះស្រាយ ?

ចិន ចចេស ក្នុង សេចក្ដីកាន់ច្រឡំ របស់ខ្លួន ក្នុងសង្គ្រាម រំដោះ ស្រុកខ្មែរ ពី ការកាន់កាប់ នៃ កងទ័ពយួន ក្នុង អំឡុងឆ្នាំ ១៩៧៩ ដល់ ១៩៨៩ ដោយ បន្តគាំទ្រ គណបក្សកុម្មុយនិស្តខ្មែរ ជា បក្សដឹកនាំ រដ្ឋកម្ពុជា ប្រជាធិបតេយ្យ ជា តំណាងប្រជាជាតិខ្មែរ នៅ អ.ស.ប. (O.N.U.) ហើយ ជួយឧបត្ថម ត្រាប់ បែបយ៉ាង ដល់ កងទ័ពសេសសល់ របស់ខ្មែរក្រហម ១មានជំហរ ជា កងទ័ពចម ក្នុងចំណោម កងទ័ព នៃ ចលនា តស៊ូ រំដោះ មាន កងទ័ព សីហនុនិយម នៅក្រោមបញ្ជាការ ទ្រង់ រណឫទ្ធិ និង រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ដឹកនាំ ដោយ សម្ដេច សីន សាន។ អាមេរីកាំង ជួយដល់ ការតស៊ូ នោះ តាម គោលការណ៍ នៃច្បាប់អន្តរជាតិ ដោយផ្ដន្ទាទោស ប្រទេសវៀតណាម ដែលបានឈ្លានពាន នូវ អធិបតេយ្យភាព និង បូរណភាពទឹកដី នៃ កម្ពុជា តាមកម្លាំងយោធា តែ អាមេរីកាំង ក្ដាន គោលដៅ នឹងរឹលក្រឡប់ ចូលមកក្នុង ទាំនាស់ ឥណ្ឌូចិន វិញ នោះទ្បើយ។ រីឯ សមាគម នៃ ប្រទេស អាស៊ីភាគអគ្នេយ៍ (ASEAN) វិញ គាំទ្រដល់ ការតស៊ូខ្មែរ តាម កំរិត ខុសគ្នា ព្រោះ មានប្រទេសខ្លះ មាន ប្រតិកម្មអាឡែហ្ស៊ី នឹងចិនកម្មុយនិស្ត។ ប្រទេសថៃ ដែលមានព្រំដែនជាប់នឹង ស្រុកខ្មែរ ចាំបាច់ជួយដល់ ការតស៊ូខ្មែរ ដោយប្រយោល ព្រោះ ទុក នូវ ពាលក្ការ (menace) នៃ ប្រទេស វៀតណាមកុម្មុយនិស្ត មកលើ សន្ដិសុខ របស់ខ្លួន ជា ការពិត។ បំណែក ជា បីកងទ័ព នៃ ចលនា តស៊ូខ្មែរនោះ ជា ឫស នៃ អកុសល របស់ចលនា តស៊ូ

តើវាពិត ជា ដំណោះស្រាយ ?

តែម្តង នៅចំពោះមុខ កងទ័ពយួន ឈរជាប់នៅក្នុងស្រុកខ្មែរ ក្នាន សត្រូវក្នុងរំខាន ព្រោះ ប្រជាជនខ្មែរ រស់នៅក្រោម ការ កាន់កាប់ របស់ខ្លួន ទុក ការរឹលក្រឡប់ នៃ របបខ្មែរក្រហម ជា អ្វីអាចមានបាន។ ដូច្នេះ នាំគ្នាបះបោរ ប្រឆាំងយួន គឺ ប្រៀប ដូចជា ហៅ ខ្មែរក្រហម ១មកអារ-ក ខ្លួន តែម្តង។ ដូចនេះ ឈ្មោះ សម្តេច សីហនុ នៅពេលនោះ លែងអាចទុកជាការធានា ដល់ សុវត្ថិភាព ខ្លួននោះទ្បើយ ព្រោះខ្លួនធ្លាប់ស្គាល់រួចម្តង ហើយ នៅឆ្នាំ ១៩៧៥ នៃ ភ្លីនាទី ជា តុក្កតា របស់សម្តេច សីហ នុ ជា ប្រធាន នៃ រណសិរ្ស្ររួបរួមជាតិកម្ពុជា ប្រឆាំងនឹង សាធារណរដ្ឋខ្មែរ។

បំណែក នៃ ចលនាតស៊ូខ្មែរ

ម្យ៉ាងទៀត បំណែក ជា បី ភាគី នយោបាយ នៅក្នុង ក្របខណ្ឌ នៃ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ១៩៩១ របស់ចលនា តស៊ូ នៅ ចំពោះមុខ ភាគីនយោបាយ អ្នកនិយមយួន ឬ ភាគី ភ្នំពេញ ជា កំបិត មុខពីរ អាច១ភាគីនេះ មានលទ្ធភាព ប្រើ យុទ្ធសាស្ត្រ ‹បំបែកបំបាក់ ដើម្បី ត្ពួតត្រា› បានយ៉ាងងាយ ស្រួលបំផុត ដោយអាស្រ័យទៅលើ ចរិតអាត្មានិយម របស់ស ម្តេចសីហនុ និង នត្ថិភាព នៃ កម្លាំងនយោបាយ របស់ភាគី ខ្មែរក្រហម នៅក្នុងស្រុក និង លើ ឆាកអន្តរជាតិ នៅពេល នោះ។ តែ ការភ្ជាក់ផ្ទើល ដ៏ត្រកាលមួយ គឺ ចិន ចោះបង់ ភាគី ខ្មែរក្រហម នៅចំពេលដែលភាគីនេះ ត្រូវការចិនចាំបាច់ ដែល

តើវាពិត ជា ដំណោះស្រាយ ?

នាំឲភាគីនេះ បែកបាក់ផ្ទៃក្នុង រហូតមាន ឃាតកម្ម នៃ ក្រួសារ លោក សុន សេន ពីសំណាក់ ក្រុម តាម៉ុក និង បន្ទាប់មកទៀត មានឃាតកម្មអាថ៌កំបាំង នៃ ប៉ុល ពត ថាស្លាប់ដោយជម្ងឺ។ ការបោះបង់ នេះ វាយឺតពេលវេលា សំរាប់ ក្តាប់នយោបាយខ្មែរ ព្រោះ យួន ក្តាប់បានមុនទាំងអស់រួចហើយ រហូត ចាប់យក ស ម្តេច សីហនុ បានថែមទៀត។

ម្លោះហើយ ភាគីខ្មែរក្រហម ក្លាយជា ភាគី បន្ទាប់បន្សំ ធ្វើពហិ ការ នូវ ការបោះឆ្នោត នៅឆ្នាំ ១៩៩៣ ក្រោម ការរៀបចំ និង ត្រួតពិនិត្យ ដោយ អុនតាក់ (UNTAC) ហើយ មន្ត្រី ស៊ីវិល និង យោធា មួយចំនួន នាំគ្នា ចរចារៀងៗខ្លួន ចេញមុខក្តី ឬ លាក់ មុខក្តី សូមចុះចូល ជាមួយ ភាគី ភ្នំពេញ។ រីឯ អ្នកដឹកនាំ កំពូល វិញ បែកបាក់គ្នា រកផ្លូវដើររៀងៗខ្លួន សម្ងំរស់ នៅតាម ដំបន់ របស់ខ្លួន។ តែ នៅក្នុងស្ថានការណ៍បែបនេះ ពួកគាត់ បានបោះខ្លួនឯង ទៅក្នុង កណ្តាប់ដៃ អ្នកឈ្នះ និងច្បាប់អន្តរ ជាតិ ដោយកំហុស មិនចេះ ធ្វើបរិវត្ត ឲទាន់ពេលវេលា នូវ គណ បក្សបដិវត្តហ៊ីង្សា ឲក្លាយ ជា គណបក្សនយោបាយ ដែលនាំឲ ពួកគាត់ លុប ខ្លួនឯងចោល និង សម្លាប់ លទ្ធិនយោបាយ និង អង្គការ នៃ បក្ស។ ការណ៍នេះ ទុកដូច ជា ការបាក់ទ័ព តែម្តង។

ទោះបី គណបក្ស ហ្ជ៊ុនស៊ីនបុិច ឈ្នះឆ្នោត នៅឆ្នាំ ១៩៩៣ (ចំនួនសន្លឹកឆ្នោត ១.៨២៤.១៨៨) តែ គណបក្សប្រជាជនកម្ព

តើវាពិត ជា ដំណោះស្រាយ ?

ជា ស្ថិតនៅជា អ្នកចាញ់ សកម្ម[2] (ចំនួនសន្លឹកឆ្នោត ១.៥២២.៤៧១) នៅចំពោះមុខ ថ្នាក់ដឹងនាំ នៃ អ្នកឈ្នះ រាំរៀល[3] ដែលជា កំណើត នៃ រដ្ឋាភិបាល ក្បាលពីរ និង មូលហេតុ នៃ រដ្ឋប្រហារ នៅឆ្នាំ ១៩៩៧។ ដូច ពួកអ្នកដឹកនាំខ្មែរក្រហម ពួកអ្នកដឹកនាំ គណបក្ស ហ្វ៊ុនស៊ីនប៉ិច ចោះខ្លួនឯង ទៅក្នុង ទ្រុងយួនកុម្ម៉ូ និស្ត ប្ដូរយក សំបក នៃ រាជាធិបតេយ្យ សំរាប់ បុគ្គល សម្ដេច សីហនុ ដែលជា ផ្ទូរ ដើរទៅរក ប៉ាន ១ សំរាប់ដុតខ្លួនឯង ព្រោះ យួន គេមិនខ្លាចដូរ សំបក អំណាច ក្រាន់តែមានពណ៌ ឆើត ឆាយណ្ណមើល តែគ្មានរស់ជាតិ យក សាច់អំណាច មាន រ៉ាមីន សំរាប់ ចិញ្ចឹម គោលប់ណងទឹកដី របស់គេ នោះឡើយ។

ដូច្នេះ ទាំងភាគី ហ្វ៊ុនស៊ីនប៉ិច ទាំង ភាគី ភ្ជុំពេញ នាំគ្នា ចោះបង់កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា នាំគ្នាយក ការ សម្ងុះសម្ងួលគ្នា នៃបដិប្រជាធិបតេយ្យ រហូត ហ្វ៊ុនស៊ីនប៉ិច ដែលជា គណបក្សនិយម រាជានិយម រលាយខ្លួន ជាគណបក្ស នយោបាយ រួមកាន់អំណាច ដល់ទៅគ្មាន អាសនៈ នៅក្នុង សភាជាតិ តែម្ដង។ តើការណ៍នេះ មិនមែនជា លក្ខណៈ នៃ រាជានិយមខ្មែរ ទេហ:?

មកដល់ គណបក្សសង្គ្រោះជាតិ ដែលជា ការគួបផ្ទ្ប់គ្នា រវាង គណបក្សសមរង្សី នឹង សិទ្ធិមនុស្ស។ គណបក្សទាំងពីរនេះ ធ្លាប់

---

[2] Vaincu agissant.

[3] Vainqueurs hésitants.

តើវាពិត ជា ដំណោះស្រាយ ?

មាន អាសនៈ រៀងៗខ្លួន នៅរដ្ឋសភាព ក្នុង អាណត្តិទី៤ : ២៦ កៅអី និង ៣ កៅអី។ ជា អាពាហ៍ពិពាហ៍ នៃ សេចក្ដីស្នេហា ឬ សំរាប់បូកសន្ទឹកនោ្នត ដើម្បី ទាញយកចំនួនកៅអីសភា ១ បានច្រើនដាច់ខាត ? តែទោះបី នៅក្នុងប្រការ ណាមួយក៏ដោយ គណបក្សនេះ បានឈ្នះនោ្នត នៅឆ្នាំ ២០១៣។ ជាជ័យជំនះមួយដ៏ធំធេ សំរាប់ដំណើរ នៃការកសាង លទ្ធិប្រជាធិបតេយ្យ។ តែជាអកុសល ថ្នាក់ដឹកនាំ មិនយកកម្លាំង ដែលជាកម្លាំងធនៈ នៃ ប្រជាពលរដ្ឋខ្មែរ ទៅទប់នឹង កម្លាំងអំណាចផ្តាច់ការ ប៉ែរជា ទៅយក ការឃុបឃិត ជាមួយវា ដើម្បី យសស័ក្ដិ ដោយ សុខចិត្តទទួលស្គាល់ខ្លួន ជា អ្នកចាញ់ ហើយ នាំគ្នាដើរចូលរដ្ឋសភា ទទួលយកកៅអី ដែល គេកំរិតចំនួនអោយ។ ពួកគាត់ យកធនៈប្រជាពលរដ្ឋ ទៅប្ដូរនឹង ធនៈ ពួកអ្នកផ្តាច់ការ ដែលនាំឲពួកនោះ អាចរក្សា ភាពស្របច្បាប់របស់គេ។ ដូច្នេះ អ្វីដែលកំពុងកើតឡើងសព្វថ្ងៃ ដូចយ៉ាង លោក សម រង្សី បាត់ដំណែងជា ប្រធានគណបក្ស រហូតដល់ទៅសូមលាលែងពីសមាជិកបក្ស ដោយហេតុផ្ទាល់ខ្លួន (?) និង លោក កឹម សុខា ត្រូវ អាជ្ញាធរ នៃ អំណាចផ្តាច់ការ ចាប់ដាក់គុក និង ព្រះមហាក្សត្ស ចុះហត្ថលេខា ទទួលឲអនុវត្ត ច្បាប់រំលាយគណបក្ស និងចែក អាសនៈ គណបក្សណា ដែលត្រូវបានរំលាយ គឺជាកម្មវិបាកផ្ទាល់ របស់នយោបាយ ថ្នាក់ដឹកនាំ នៃ គណបក្សសង្គ្រោះជាតិ។ ការបន្តបន្ទមាន ព្រឹត្តិការណ៍ មហន្តរាយ ដល់ប្រជាជាតិខ្មែរសព្វថ្ងៃ ថ្នាក់ដឹងនាំ គណបក្សសង្គ្រោះជាតិ ភ្ជាន

តើវាពិត ជា ដំណោះស្រាយ ?

គម្ពាស់ (levier) ណាមួយពិតប្រាកដ ក្រៅពី ដេកសង្ឃឹម លើតែ វិធានការអន្តរជាតិ ដែល វាប្រហែលជាអាចមាន ឬ គ្មាន តែ ប៉ុណ្ណោះ។

ទម្លាប់ នៃ ដំណោះស្រាយ

នៅក្រៅប្រទេស លោក សម រង្សី ជាទម្លាប់របស់គាត់ គឺ យក បញ្ហាផ្ទាល់ខ្លួន ទៅផ្ទាប់នឹង បញ្ហាជាតិ ពោលថា បើ លោក ហ៊ុន សែន បញ្ជប់ នូវ ទំនាស់ជាមួយគាត់ គឺ គាត់នឹងផ្តល់ នូវ ចំណេញនយោបាយ១រាញ់ជានិច្ច ហៅថា ‹ទ្រឹស្តី អោយគ្នាទៅវិញ ទៅមក ឬ ចែកចំណេញគ្នា›។ ទ្រឹស្តីនេះឯង ជា យីហោ នយោបាយ របស់លោក សម រង្សី។

រីឯ លោក កឹម សុខា វិញ កាលណា ជាប់អន្ទាក់ លោក ហ៊ុន សែន ម្តងៗ ក្នុងបញ្ហាណាមួយ គាត់ មាន គោលវិធី ពិសេស របស់គាត់ ដើម្បី រំដោះខ្លួន ១រួចចេញផុតពីអន្ទាក់ គឺយក ការ សន្យា សម្រេបតាមចិត្តដៃគូសិន ជា មធ្យោបាយ ដោះស្រាយប ញ្ហា។ ‹ធ្វើសិន› នេះឯង ជា យីហោ នយោបាយ របស់លោក កឹម សុខា។

ត្រូវដឹកថា លោក សម រង្សី និង កឹម សុខា ជា ដៃគូនយោបាយ របស់លោក ហ៊ុន សែន ដែលយួនកុម្ម្ងយនិស្ត គេចិញ្ចឹម ជួនគេ១ សាច់ស៊ីន្ធាញ់ ជួន គេបង្ហត់បាយ តែមិន១ស្លាប់ជាដាច់ខាត សំ រាប់ ការបោះឆ្នោត។ បើ លោក សម រង្សី គាត់ ពោលអះអាង ថា

តើវាពិត ជា ដំណោះស្រាយ ?

លោក ហ៊ុន សែន មិនអាចរំលាយ គណបក្សសង្គ្រោះជាតិ ជាដាច់ខាត វាជាសំដីពិត ព្រោះ ការរំលាយ ឬ ការមិនរំលាយ វាអាស្រ័យ ទៅលើ ប្រយោជន៍ របស់លោក ហ៊ុន សែន, បើគេមិនរំលាយ គឺធ្លាស់ជាគេ មាន មធ្យោបាយគ្រប់គ្រាន់ សំរាប់ទុកគណបក្សនេះ បំរើប្រយោជន៍ឃ្លួន ដូចសព្វដង។ បើតាមការពិសោធ លោក សម រង្សី គឺជា កូនអុក សំរាប់ លោក ហ៊ុន សែន យកមកដោះស្រាយ។ ការណ៍នេះ វាជា ទម្លាប់ មាន តាំងពីយូរយ៉ាណាស់មកហើយ។ ត្រូវដឹកថា លោក សម រង្សី និង លោក កឹម សុខា គាត់ មុនជា ជនរងគ្រោះ នៃ ទង្វើខូច របស់លោក ហ៊ុន សែន គឺ គាត់ បានសេពគប់នឹង ចារី នៃ ទង្វើ។ គាត់ ទទួលយកទាំងអស់ ហើយ នាំគ្នា ធ្វើឲវាស្រេបធ្លាប់ ជានិច្ច។ គាត់ ដាំ នូវ អំពើ អកុសល ក្នុង ចំការ នៃ រឬជម៌សន្ទនា ដែលជា គោលការណ៍ នៃ ឧត្ថាត ដល់ លទ្ធិប្រជាធិបតេយ្យ : នាំគ្នាក្បត់ម្ចាស់ឆ្នោត ដើម្បី កៅអីអាម៉ាស់ក្ដ្ដ ដែល លោក ហ៊ុន សែន ឃ្លន់ពីរាស្ត្រ យកមកឲពួកគាត់ សំរាប់លំអ អំណាច ដូចយ៉ាង លោក កឹម សុខា គាត់ ទទួលយកជានិច្ច នូវ អំណោយ នៃ ហានន្ទ្ររស័ក្ដិ ដែល ហ៊ុន សែន ឲគាត់ ទោះបី ជា កៅអី សំរាប់ផ្ទាត់គាត់ឲធ្លាក់ភក់ក៏ដោយ និង លោក សម រង្សី ទទួល កៅអីដំណាងរាស្ត្រ ដោយ ឥតចាំបាច់ មានឈ្លោះក្នុង បញ្ជីបេក្ខជនតាម ការសម្រុះសម្រួល ដោយ ឥតយកច្បាប់ មកធ្វើជាមូលដ្ឋានសោះឡើយ។ បើ បេក្ខភាព លោក សម រង្សី ត្រូវបាន គ.ជ.ប. ដកចេញ ត្រូវដាក់ចូលវិញ ហើយ ចោះឆ្នោត យ៉ាងហោច

តើវាពិត ជា ដំណោះស្រាយ ?

ណាស់ សំរាប់ មណ្ឌល ដែល លោក សម រង្សី ឈរឈ្មោះ ទើប គាត់ ជា តំណាងរាស្ត្រ ស្របច្បាប់ ដែល គ្មាន ស្ថាបនណា អាចដក ហូត អាណត្តិ របស់គាត់បាននោះឡើយ ពុំនោះសោធ វាគ្មានអ្វី ច្បាស់លាស់នោះឡើយ។ ច្បាប់ គឺ វាជា ច្បាប់ មិនអាចនិយាយ ថា បើសិន នោះបានឡើយ។

យើង នាំគ្នា គិត ជា គំនិតថា វាជ្រុលទៅចុះ ថា បើមានការ សម្រុះសម្រួល ជាថ្នីរវាង គណបក្សកាន់អំណាច នឹង សង្គ្រោះ ជាតិ ដូចយ៉ាង ដោះលែងលោក កឹម សុខា ពីគុកនយោបាយ លោក សម រង្សី ចូលស្រុកបានវិញ តើ វាមាន អ្វី ដែលជាសេច ក្តីសង្ឃឹម ដល់ ប្រជារាស្ត្រខ្មែរទៅ ក្រៅពីនាំគ្នា ធ្វើការបោះឆ្នោត គ្មានសេរី និង គ្មានយុត្តិធម៌ សំរាប់ឃ្លីនឈ្នះ តែប៉ុណ្ណោះ ព្រោះ លោក សម រង្សី និង កឹម សុខា គាត់ សូមតែប៉ុណ្ណោះឯង។ ឧទាហរណ៍ ជាការស្ថានថា លោកទាំងពីរ ជំពាក់លុយ លោក ហ៊ុន សែន តែ ១០០€ តែ លោក ហ៊ុន សែន ចោទថា ១.០០០€ តែ ក្នុង ការសម្រុះសម្រួលនោះ លោក ហ៊ុន សែន ថា សង តែ ៥០០€ ក៏បានដែរ ក៏លោកទាំងពីរ គាត់សុខចិត្តសងដែរ។ នេះ ហើយ ដែលជាដំណោះស្រាយ អាចកើតមានឡើង ជាថ្នី នៅ ក្រោម ការទទួល នៃ ការសរសើរ ឬ អបហាស ពីសំណាក់ សហ គមអន្តរជាតិ ថាខ្មែរ ចេះរួបរួមគ្នា។ តើ ការរួបរួមនោះ អ្នកណា ជាអ្នក ទទួលបានចំណេញ ដាច់មុខ ?

ឯកសារវ៉ាក

ដកស្រង់ពី ខ្លឹមសារ នៃ កិច្ចព្រមព្រៀង នៅ ប៉ារីស រវាង សហរដ្ឋអាមេរិក នឹង វៀតណាមខាងជើង ដែលបាន ចុះហត្ថលេខា នៅថ្ងៃ ទី២៧ ខែ មករា ១៩៧៣ ក្នុងវគ្គទី៧, មាត្រា២០ ស្តីពី កម្ពុជា និង លាវ :

ក/ ភាគីទាំងឡាយ ដែលបានចូលរួមសន្និសិទនៅ ប៉ារី ស្តីពី វៀតណាម ត្រូវគោរពយ៉ាងម៉ត់ចត់ ដល់កិច្ចព្រមព្រៀង ហ្ស៊ឺណែវ នៅឆ្នាំ ១៩៥៤ លើកម្ពុជា និង កិច្ចព្រមព្រៀងហ្ស៊ឺណែវ នៅឆ្នាំ ១៩៦២ លើ លាវ ដែលជា កិច្ចព្រមព្រៀង ដែលធ្វើ១មាន ពិតប្រាកដ នូវ សិទ្ធិប្រជាជាតិ ជាឫសគល់ នៃ ប្រជាជន កម្ពុជា និង លាវ គឺ ឯករាជ្យ, អធិបតេយ្យភាព, ឯកភាព និង បូរណភាពទឹកដី នៃ ប្រទេសទាំងពីរ។ ម្ហ្លោះហើយ ភាគីទាំងឡាយ ត្រូវគោរព នូវ អព្យាក្រិតភាព នៃ កម្ពុជា និង លាវ ដោយ សន្យាថា មិនប្រើទឹកដី កម្ពុជា និង លាវ ដើម្បី ធ្វើ១ប៉ះពាល់ទៅវិញទៅមក ដល់ អធិបតេយ្យភាព និង សន្តិសុខ នៃ ប្រទេសទាំងពីរ និង ប្រទេសឯទៀត។

ខ/ បរទេសទាំងឡាយ នឹងបញ្ចប់ សកម្មភាពយោធាទាំងអស់ នៅ កម្ពុជា និង លាវ និង ដកចេញទាំងអស់ ពីប្រទេសទាំងពីរ នេះ នូវ កងទ័ព, ទីប្រឹក្សាយោធា, បុគ្គលិកស៊ីវិល, អាវុធយុទ្ធភ័ណ្ឌ ហើយនឹង មិនបញ្ជូលជាដាច់ខាតមកទៀតឡើយ។

តើវាពិត ជា ដំណោះស្រាយ ?

ក/ កិច្ចការផ្ទៃក្នុង នៃ កម្ពុជា និង លាវ ត្រូវប្រជាជនទាំងពីរ ជា អ្នកចាត់ចែងរៀងៗខ្លួន ដោយឥតមាន ការជ្រៀតជ្រែក ពីបរទេស នោះទ្បើយ។

ឃ/ ចំណោទទាំងឡាយ ដែលនៅមានជាប់ជំពាក់នឹង ទំនាក់ទំនង រវាង ប្រទេស នៃ ឥណ្ឌូចិន នឹងត្រូវ ដោះស្រាយ ដោយ ភាគីឥណ្ឌូចិន លើ មូលដ្ឋាន នៃ ការគោរព ទៅវិញទៅមក ដល់ឯករាជ្យ, អធិបតេយ្យភាព, បូរណភាពទឹកដី និង ការមិនជ្រៀតជ្រែក ដល់កិច្ចការផ្ទៃក្នុង នៃ ប្រទេសនិមួយៗ។